## តំបន់វិទ្យាសាស្រ្ត និងតំបន់ធម្មជាតិ

តំបន់ធម្មជាតិ និងតំបន់វិទ្យាសាស្រ្ត គឺជាផ្ទៃដីនៃសាធារណៈ ដ៏ផ្នែកមួយដែលបានធ្វើឱ្យក្លាយ ទៅជាកន្លែងមួយ ដើម្បីរក្សនូវធនធានធម្មជាតិ ។ ពីព្រោះវាមានសញ្ញាជាតិពិសេសដែលមានតំលៃបំផុត និងកម្ររកបាននៅក្នុង រដ្ឋមីនីសូតា ។ តំបន់ធម្មជាតិ និងតំបន់វិទ្យាសាស្រ្ត មានចំនួនជាង ១២៥ កន្លែង ដែលស្ថិតនៅពាសពេញក្នុងរដ្ឋ ។



ឧទាហរណ៍ដូចជា ៖

នៅវាលស្មៅ ដ៏ធំធេងដែលស្ថិត នៅទិសខាងត្បូងឈាងខាងលិច (និរតី) នៃរដ្ឋមីនីសូតា គឺជាទីជំរកនៃសត្វមេអំបៅ ដែលកម្រមានណាស់ ។

រីឯទិសខាងជើងនៃរដ្ឋមីនីសូតាវិញ គឺមានដើមស្រល់ជាច្រើន សម្បុលស ដែលដុះជាច្រើនសតវត្សមកហើយ នៅតាមជ្រលងជ្រោះជ្រៅ ។

ចំណែកទីក្រុងវិញ មានព្រៃសេនជាច្រើន ដែលមានភាពស្ងប់ស្ងាត់ ហើយសំបូរណ៍ទៅដោយផ្កាព្រៃគ្រប់ប្រភេទ ដុះរីកលូតលាស់ស្រស់បំព្រង នៅក្នុងរដូវរំហើយ ។ តំបន់វិទ្យាសាស្រ្ត និងតំបន់ធម្មជាតិ គឺពិតជាកន្លែង ដ៏មានតំលៃយ៉ាងពិសេសនៃរដ្ឋ ហើយកន្លែងនោះស្ថិតនៅក្រោមការថែរក្សានៃ កម្មវិធីដ៏ពិសេសរបស់ ក្រសួងធនធានធម្មជាតិ ដែលហៅថា កម្មវិធីនៃតំបន់វិទ្យាសាស្រ្ត និងតំបន់ធម្មជាតិ ។ គោលដៅនៃតំបន់វិទ្យាសាស្រ្ត និងតំបន់ធម្មជាតិគឺដើម្បីការពារទីកន្លែងធម្មជាតិ ដែលគ្មានអ្នកណារំខានឱ្យបានថិតថេរ គឺជាកន្លែងដែលមានតំលៃ ខាងវិទ្យាសាស្រ្តឬការសិក្សា ។

## គោលដៅនៃតំបន់វិទ្យាសាស្រ្ត និងតំបន់ធម្មជាតិ

តំបន់ធម្មជាតិ នៃរដ្ឋមីនីសូតា បានបង្កើតឡើងដោយមានបំណងជាច្រើនយ៉ាង ដូចជា ៖

១. ផ្តល់ទីកន្លែងសំរាប់ សាធារណៈក្នុងការទស្សនា នូវទិដ្ឋភាពដំណាំរុក្ខជាតិដែលកម្រមាន និងសត្វប្លែកៗជាច្រើន ឬក៏អាចសិក្សាអំពីធម្មជាតិដោយខ្លួនឯង នៅក្នុងទីធ្លា យ៉ាងសមរម្យ ទាំងមានការចាប់អារម្មណ៍ និងកោតសរសើរក្នុងចិត្ត ។

២. ផ្តល់ទីកន្លែងសំរាប់អ្នកវិទ្យាសាស្រ្ត ទៅចំរើនចំណេះវិជ្ជាឱ្យបានជ្រួតជ្រាបតាមក្បួនធម្មជាតិ និងអាចដកស្រង់ពត៌មានផ្សេងៗអំពី បរិយាកាសដែលកខ្វក់ ឬវាស់ស្ទង់នូវបរិយាកាសដែលមានការផ្លាស់ប្តូរជាលំដាប់ ។

៣. ផ្តល់នៅថ្នាលដំណាំរុក្ខជាតិ និងសម្ភារៈសម្រាប់ថែទាំសត្វដែលអាចផ្តល់អត្ថប្រយោជន៏ នៅថ្ងៃអនាគត សម្រាប់បង្កើតថ្នាំដង្កូវថ្មី ហើយក៏អាចផ្តល់ផលប្រយោជន៏ ជាច្រើនយ៉ាងសំរាប់កសិកម្ម និងឧស្សាហកម្ម ។

៤. ដើម្បីការពារនូវវត្ថុដ៏ល្អ ដែលមាននៅសេសសល់ ដូចជារុក្ខជាតិ កម្រមាននៅលើសទាប់ផែនដី និងសត្វចម្លែកៗ និងរុក្ខជាតិចំរុះពូជ ជាពិសេសវត្ថុធាតុដើម ដែលមានសារជាតិជាថ្នំតែមានរស្មី ចំណាំងភ្លឺផ្លេកៗ ។



## តើមុខងារយើងជាអ្វី?

យើងជាពលរដ្ឋ នៃរដ្ឋមីនីសូតា ។ យើងម្នាក់ៗចាំបាច់ត្រូវមានការទទួលខុសត្រូវដោយខ្លួនឯង ដើម្បីជួយថែរក្សានូវធនធានធម្មជាតិដ៏ល្អ ហើយយ៉ាងវិសេសវិសាល ប្រយោជន៏ជួយដល់សត្វទាំងឡាយ និងដំណាំផល្លាទាំងពូងឱ្យគង់វង់ ដ៏យូរអង្វែងដ៏រាបទៅថ្ងៃក្រោយព្រមទាំងដំណារពូជ ទៅថ្ងៃខាងមុខទៀតផង ។ កម្មវិធីនៃតំបន់វិទ្យាសាស្រ្ត និងតំបន់ធម្មជាតិនៃក្រសួងធនធានធម្មជាតិគឺមានមុខងារទទួលខុសត្រូវនូវវត្ថុ ដែលរកបានមក និងការធ្វើប្លង់ ហើយការគ្រប់គ្រងតំបន់ធម្មជាតិរបស់រដ្ឋ ។ តំបន់វិទ្យាសាស្រ្ត និងតំបន់ធម្មជាតិ បានបើកចំហរជាសាធារណៈសំរាប់បងប្អូនជនរួមជាតិដើម្បីសង្កេតមើលធម្មជាតិ ធ្វើការសិក្សា និងការស្រាវជ្រាវ ។ល។ យើងសូមជំរាបនិងជួយជំរុញ ទឹកចិត្តបងប្អូនជនរួមជាតិគ្រប់រូប ឱ្យចេះក្រេបជញ្ជក់នូវការសិក្សា និងការស្វែងយល់ដើម្បីរកវត្ថុទាំងអស់នោះ ប៉ុន្តែសូមឱ្យបងប្អូនប្រើប្រាស់ឱ្យបានថ្នាក់ថ្នមក្រែងលោបាក់បែក ។ យើងសូមឱ្យបងប្អូនជនរួមជាតិមេត្តាគោរពតាមក្រិតក្រម នៃច្បាប់រដ្ឋ និងសូមរាយការណ៍នូវរាល់ហេតុការណ៍ ដែលកើតមានឡើងជាបញ្ហាដោយអំពើរបស់អ្នកដ៏ទៃ បានប្រព្រឹតខុសជូនដល់ អង្គការរដ្ឋទុកជាដំណឹង ហើយក៏សូមជួយផ្សព្វផ្សាយ ដល់អ្នកដ៏ទៃអំពីសារៈសំខាន់នៃតំបន់នេះផងដែរ ។

## តើច្បាប់បញ្ញត្តិមានអ្វីខ្លះ?

១.  បងប្អូនមិនអាចប្រមូល បិចបោចដំណាំ ឬក៏ចាប់សត្វអ្វីពីតំបន់វិទ្យាសាស្ត្រ និងតំបន់ធម្មជាតិបានឡើយ ។

២.  បងប្អូនមិនអាចបាញ់សម្លាប់សត្វ ឬក៏ស្ទូចត្រី ។

៣.  បងប្អូនមិនអាចបោះតង់ ធ្វើជាជុំរុំកែកំសាន្ត ឬក៏ដុតអាំងសាច់សំរាប់ទទួលទាន ក្នុងពេលសំរាកកាយ នៅក្នុងបរិវេណទីធ្លានោះបានឡើយ ។

៤.  មិនអនុញ្ញាតិឱ្យមានយានជំនិះ ដែលបំពាក់ដោយគ្រឿងម៉ាស៊ីន ដូចជាឡាន ម៉ូតូ ឆ្លងកាត់បរិវេណនោះបានជាដាច់ខាត ។

បើបងប្អូនមានបំណង នឹងទៅតំបន់កំសាន្ត នៅក្នុងតំបន់ វិទ្យាសាស្ត្រ និងតំបន់ធម្មជាតិ ដោយចង់ឃើញធនធានធម្មជាតិដ៏ល្អនៃរដ្ឋមីនីសូតា នៅក្នុងថ្ងៃណាមួយនោះ សូមសប្បាយតាមសេរី ហើយសូមជួយការពារថែរក្សាទីកន្លែងនោះឱ្យមានសុវត្ថិភាពផង ។

ពតិមានស្តីអំពីតំបន់វិទ្យាសាស្ត្រ និងធម្មជាតិនៃរដ្ឋមីនីសូតា សូមទាក់ទងនឹង ៖

កម្មវិធីនៃតំបន់វិទ្យាសាស្ត្រ និងធម្មជាតិ នៃក្រសួងថែរក្សាសម្បត្តិធម្មជាតិ រដ្ឋមីនីសូតា ផ្នែក អេកូឡូស៊ី អាស័យដ្ឋាន

**Scientific and Natural Areas Program**
**MN Department of Natural Resources**
**500 Lafayette Road, Box 25, St. Paul, MN 55155-4007**
**សូមទាក់ទងតាមទូរស័ព្ទលេខ (651) 297-2357**

Scientific and Natural Areas Program
Minnesota Department of Natural Resources
Section of Ecological Services
500 Lafayette Rd. Box 25
St. Paul, MN 55155-4007



# តំបន់វិទ្យាសាស្ត្រ និងតំបន់ធម្មជាតិ

# Scientific and Natural Areas



Minnesota Department of Natural Resources

Cambodian